# ៤. លទ្ធផលនៃការស្រាវជ្រាវ

## ៤-១ លក្ខណៈជីវរូបរបស់ភូមិសាស្រ្ត (Biophysical Characteristics)

### ៤-១-១ អាកាសធាតុ

#### ៤-១-១-១ សីតុណ្ហភាព និងសំណើមបរិយាកាស

**១២២.** សីតុណ្ហភាពមានលក្ខណៈខុសគ្នាតិចតួចទៅតាមអន្តរតំបន់ជាងកត្តាបរិស្ថាន និងថាវរូបបន្តផ្សេងៗទៀតដែលអាចមានឥទ្ធិពល។ ភាពខុសគ្នាខ្លាំងរបស់សីតុណ្ហភាពអាចបណ្តាលមកពីទីតាំងភូមិសាស្រ្ត ពោលគឺរយៈកំពស់ និងគំរបពពកដែលមានការផ្លាស់ប្តូរតាមរដូវកាល។ តាមការសិក្សាអំពីសីតុណ្ហភាពនៅពោធិនតុងនៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ[១] ១បង្ហាញថា សីតុណ្ហភាពអតិបរិមាគិតជាមធ្យមនៅក្នុងឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ៣២,៥-៣៣,៧០អង្សាសេ (សីតុណ្ហភាពអតិបរិមាមានការប្រែប្រួលក្នុងចន្លោះខែមេសា-ឧសភា ក្នុងនោះមានឆ្នាំ ខ្លះសីតុណ្ហភាពបានឡើងដល់៣៧,១០អង្សាសេ) ចំណែកឯសីតុណ្ហភាពអប្បរមា គិតជាមធ្យមនៅក្នុងឆ្នាំមានការ ប្រែប្រួលក្នុងចន្លោះ ២៣,៨០-២៥,៨០អង្សាសេ (សីតុណ្ហភាពអប្បបិរមាមានការប្រែប្រួលក្នុងចន្លោះខែធ្នូ-មករាក្នុងនោះមានឆ្នាំខ្លះសីតុណ្ហភាពបានធ្លាក់ចុះដល់២០,៦ អង្សាសេ) (ឧបសម្ព័ន្ធ៥-១)។ អាកាសធាតុនៅ ក្នុងប្រទេសជាទូទៅមានលក្ខណៈជាអាកាសធាតុបែប សំណើមត្រូពិក ឬមូសុងត្រូពិក (Humid-Tropical or Tropical Monsoon) ជាអាកាសធាតុក្តៅ-សើម ដែលមានការប្រែប្រួលទៅតាមទីតាំងភូមិសាស្រ្ត។ តាមរយៈ ការសិក្សាទៅលើសំណើមបរិយាកាសនៅស្រុក ឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ (ទិន្នន័យពីស្ថានីយ៍កំពត) បង្ហាញថាមធ្យមភាគរបស់សំណើមបរិយាកាសមានការ ប្រែប្រួលគួរអោយចាប់អារម្មណ៍នៅក្នុង ចន្លោះពី៧៨,០០-៨០,០០ភាគរយ (ឧបសម្ព័ន្ធ៥-២)។ ដោយសារទិន្នន័យឧតុនិយមខេត្តកំពង់ស្ពឺពុំមានគ្រប់គ្រាន់ ដូច្នេះយើងសំរេចយកតាមខេត្តកំពតព្រោះជាខេត្តដែលនៅក្បែរខាងគ្នាដែលមានទិន្នន័យប្រហាក់ប្រហែលគ្នា។

#### ៤-១-១-២ របបខ្យល់ និងរបបទឹកភ្លៀង

**១២៣.** ជាទូទៅអាកាសធាតុរបស់ប្រទេសកម្ពុជា មានលក្ខណៈខុសគ្នា និងមានការប្រែប្រួលទៅតាមទីតាំងភូមិ សាស្រ្ត។ ជាក់ស្តែងខ្យល់ស្ងួតបានបក់ពីភូមិភាគឦសាន្តទៅភូមិភាគនិរតីនៃប្រទេស ដោយមាននាំទាំងទឹកភ្លៀង តិចតួចមកជាមួយផង យើងហៅរដូវនេះថាជារដូវប្រាំង ហើយរដូវនេះមានរយៈពេល៦ខែ ចាប់ផ្តើមពីខែវិច្ឆិកា-មេសា។ ចំណែកឯរដូវវស្សាបានចាប់ផ្តើមពីខែឧសភា-តុលា ក្នុងពេលដែលខ្យល់មូសុងបានបក់

---

[១] ប្រភព: ស្ថានីយ៍ឧត្តុនិយមកំពត

Draft

ពីភូមិភាគនិរតី ឆ្ពោះទៅខ្ពង់រាបឦសាន្តនៃប្រទេស ដែលបាននាំមកនូវភ្លៀងដ៏ខ្លាំងដល់តំបន់ទំនាបកណ្តាល ហើយរបបទឹក ភ្លៀងនេះបានជះឥទ្ធិពលដល់ការរីកលូតលាស់និងដំណុះរបស់រុក្ខជាតិ។ តាមការអង្កេតអំពីល្បឿននិងទិស របស់ខ្យល់នៅឯស្ថានីយ៍ឧត្តុនិយមកំពត សំរាប់ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ នៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ បង្ហាញអោយដឹងថា: ល្បឿននិងទិសរបស់ខ្យល់គ្មាន អ្វីប្រែប្រួលគួរអោយចាប់អារម្មណ៍នោះទេ ដែលល្បឿនខ្យល់ជាមធ្យមនៅក្នុងខែនិមួយៗមានការប្រែប្រួលពី ៥.០០-១៣.០០ម/វិនាទី (ឧបសម្ព័ន្ធ៥-៣)។ តាមការអធិប្បាយរបស់លោក D.Crocker ១៩៦២ និង Anonymous, ១៩៩៧.៩៩ តំបន់ដែលទទួលភាពរាំស្ងួតជាងគេនៅក្នុងប្រទេសកម្ពុជា គឺអាងទន្លេសាបដូចជា: តំបន់ដីទំនាបភាគខាងជើង និងខាងត្បូងនៃជួរភ្នំដងរែក ដែលភាពរាំងស្ងួតបានអូសបន្លាយរយៈពេលរហូតដល់ទៅ០៦ខែ និងទទួលនូវរបប ទឹកភ្លៀងប្រចាំឆ្នាំមានកំរិតទាបជាង១.៤៧៧មម។ តាមការសិក្សាទៅលើកំពស់ទឹកភ្លៀង ដែលបានកត់ត្រានៅ ឯស្ថានីយ៍ឧតុនិយមខេត្តកំពតនៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយ (១៩៩៨-២០០៨) បានអោយដឹងថាមធ្យម ភាគកំពស់ទឹកភ្លៀងប្រចាំឆ្នាំមានការប្រែប្រួលក្នុងចន្លោះ ១៩២០.៧០-២៤៨០.១០មម (ឧបសម្ព័ន្ធ ៥-៤)។

### ៤-១-២ ភូគព្ភសាស្ត្រ និងឋានលេខា

**១២៤.** ដីសម្បទានដែលក្រុមហ៊ុន **អេចអិលអេច អេគ្រីខលឈើរ (ខេមបូឌា) ខូអិលធីឌី** ទទួលបានការប្រទានសិទ្ធិពី រាជរដ្ឋាភិបាល ដើម្បីធ្វើការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនេះមានទំហំ ៩៩៨៥ហិកតា មានទីតាំងស្ថិតក្នុង ភូមិសាស្ត្រឃុំសង្កែសាទប និងឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ដីសម្បទាននេះអាចចូលភូមិដំបងវែញ ភូមិជំនាប់ ភូមិក្រាំងពង្រ និងភូមិច្រកទៀក ដែលមានចំងាយ៣-៥គីឡូម៉ែត្រភាគខាងកើតនៃដីសម្បទានស្ថិតនៅ តាមដងផ្លូវទៅឃុំត្រពាំងជោក្នុងខេត្តកំពង់ស្ពឺ ដោយមានស្ថានភាពផ្លូវលំបាកក្នុងការធ្វើដំណើរ។ ដីនេះ មានព្រំប្រទល់ ខាងកើតជាប់នឹងដីសម្បទានរបស់ក្រុមហ៊ុន **កំពង់ស្ពឺ ស៊ូហ្គើរ** និងភូមិដំបងវែញ ច្រកទៀក និងអូរតោង និងខាងត្បូងជាប់នឹងឃុំពង្រ ចំណែក ខាងលិចជាប់នឹង ជាប់អូរសំរោង និងភ្នំរាំងកាល។ ចំពោះ ខាងជើង ជាប់ព្រំប្រទល់ឃុំសង្រែ និងឃុំព្រងិល ស្រុកភ្នំក្រវាញ (ចំណុចនិយោមកា ព្រំប្រទល់សូមមើលផែនទីឧបសម្ព័ន្ធ១-៣) ត្រង់កត្តាខណ្ឌទី៣៤ ទំព័រ ១៩-២០។

**១២៥.** ដីនេះស្ថិតនៅតំបន់វាលទំនាបភាគខាងជើងបឹងទន្លេសាបនៃប្រទេសកម្ពុជា លើរយៈកំពស់ពី២៣-៦៣ម ធៀបនឹងនីវ៉ូសមុទ្រ(ជាមធ្យមមានរយៈកំពស់៣៦ម-ទិន្នន័យGPS) ទទួលរបបទឹកភ្លៀងជាមធ្យម ២.៤៦០មម សីតុណ្ហភាពមធ្យមប្រចាំឆ្នាំខ្ពស់ជាង២៦.៤៨ ដីក្រសែលស៊ុសដែលរដូវប្រាំងមានរយៈពេលលើស ពី៤ខែ (DANIDA, 2003)។ តាមការសិក្សាបានបង្ហាញថា ឋានលេខារបស់ដីសម្បទាននេះមានលក្ខណៈរាប ស្មើសណ្ឋានដីមិនមានការប្រែប្រួលខ្លាំងគួរអោយកត់សំគាល់ទេ។ ក្រុមការងារបានពិនិត្យឃើញថាមានអូរតូចៗ ជាច្រើនប៉ុន្តែមួយចំនួន

Draft

ធំបានរីងស្ងួតអស់ហើយ ដែលបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ និងដឹកជញ្ជូន ផល-អនុផលព្រៃឈើនៅរដូវប្រាំង។ នៅរដូវប្រាំងព្រៃក្នុងតំបន់នេះតែងត្រូវភ្លើងឆេះ ជាពិសេសនៅតាមដងផ្លូវដោយសារមាន សកម្មភាពកាប់ព្រៃ និងដុតបំផ្លាញយកដីធ្វើជាកម្មសិទ្ធិ។

**១២៦.** ដីជាតិដីអាចកំណត់ដោយសិលាមេដែលមានស្ថិតនៅស្រទាប់ក្រោម និងដោយការអង្កេតទៅលើប្រភេទព្រៃគំរបព្រៃអំពីភាពបៃតងរបស់វា។ លក្ខណៈគីមីរបស់ដីតែងតែបញ្ជាក់អំពីកិរិតនិងលំនាំនៃការបំបែកធាតុរបស់សិលាមេក្នុងយុគសម័យភូគព្ភសាស្ត្រនិងលក្ខណៈរបស់ថ្មដែលជាសិលាមេ។ ដំណើរប្រព្រឹត្តទៅនៃបាតុភូគព្ភសាស្ត្រ នេះបានទទួលរងនូវឥទ្ធិពលអាកាសធាតុ ពេលវេលា ឋានលេខា និងដំណើរប្រព្រឹត្តទៅតាមលក្ខណៈជីវសាស្ត្រធម្មជាតិ លក្ខណៈជីវសាស្ត្រដែលបង្កឡើងដោយមនុស្ស សត្វ និង បាក់តេរី។ កត្តាទាំងអស់នេះអាចបញ្ជាក់ ដោយផ្ទាល់និងដោយប្រយោលអំពីដីដែលមានលក្ខណៈជាអាស៊ីត ពណ៌ រចនាសម្ព័ន្ធ ជីជាតិលទ្ធភាពផលិតកម្ម និងភាពជ្រាបទឹក។ យោងតាមផែនទីភូគព្ភសាស្ត្រ (ឧបសម្ព័ន្ធ១-ផែនទី៥) បង្ហាញថាដីសម្បទានមានសិលាមេ០៤ប្រភេទដូចជា:

| ល.រ | ប្រភេទសិលាមេ | ទំហំផ្ទៃដី (ហិកតា) | ភាគរយ (%) |
|---|---|---|---|
| ១ | Floodplain Granite | ៧៥៦.៥ | ៧.៥៧ |
| ២ | Grained granite | ៣១០.៨ | ៣.១១ |
| ៣ | Pediments | ៨៩១០.០ | ៨៩.២៣ |
| ៤ | Rhyolite | ៨.០ | ០.០៨ |
| សរុប | | ៩៩៨៥ | ១០០ |

**១២៧.** តាមរយៈការសិក្សាទៅលើលក្ខណៈរបស់ឋានលេខា និងចំណាក់ថ្នាក់ទីជំរាលបង្ហាញអោយឃើញថាសណ្ឋានដីមានភាពប្រែប្រួលខ្លាំង ហើយមានចំណាត់ថ្នាក់ទីជំរាល០៥ប្រភេទគឺ:

**ចំណាត់ថ្នាក់ទី១:** ដីសម្បទានតំបន់នេះ មានទីជំរាលចំណាត់ថ្នាក់លើសពី២០ដឺក្រេ ចំនួន ៥.២ហិកតា ឬស្មើនឹង ០.០៥ភាគរយ នៃផ្ទៃដីសរុប ដីតំបន់នេះមានលក្ខណៈចោតខ្លាំង ហើយសណ្ឋានដីមានលក្ខណៈច្រោះខ្ពស់។ សណ្ឋានដីប្រភេទនេះជានិច្ចជាកាលតែងតែជួបប្រទះនៅតាមតំបន់ខ្ពង់រាប។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ហើយធន់នឹងការហូរច្រោះខ្លាំង។ ការប្រើប្រាស់ដីតំបន់នេះ អាចមានលក្ខណៈជាការដាំឈើបែបផែនពាណិជ្ជកម្ម។

Draft

**ចំណាត់ថ្នាក់ទី២:** ដីសម្បទានតំបន់នេះ មានទីជំរាលចំណាត់ថ្នាក់ ១០-២០ដឺក្រេ ចំនួន ៣០.៦ហិកតា ឬស្មើនឹង ០.៣០ភាគរយ នៃផ្ទៃដីសរុប ដីតំបន់នេះមានលក្ខណៈចោត ហើយសណ្ឋានដីមានលក្ខណៈជ្រោះខ្ពស់។ សណ្ឋានដីប្រភេទនេះជានិច្ចជាកាលតែងតែជួបប្រទះនៅតាមតំបន់ខ្ពង់រាប។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ហើយធន់នឹងការហូរច្រោះមធ្យម។ ការប្រើប្រាស់ដីតំបន់នេះ អាចមានលក្ខណៈជាការដាំឈើបែបផែនពាណិជ្ជកម្មវាលស្មៅ ប្រសិនបើអនុវត្តវិធានការណ៍អភិរក្សបានត្រឹមត្រូវ។

**ចំណាត់ថ្នាក់ទី៣:** ដីសម្បទានតំបន់នេះ មានទីជំរាលចំណាត់ថ្នាក់ ៥-១០ដឺក្រេ ចំនួន ៧៨.៩ហិកតា ឬស្មើនឹង ០.៧៩ភាគរយ នៃផ្ទៃដីសរុប ដីតំបន់នេះមានលក្ខណៈចោតបន្តិចម្តងៗ ហើយសណ្ឋានដីមានលក្ខណៈជ្រោះទាប។ សណ្ឋានដីប្រភេទនេះជានិច្ចជាកាលតែងតែជួបប្រទះនៅតាមតំបន់ខ្ពង់រាប។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ហើយធន់នឹងការហូរច្រោះ។ ការប្រើប្រាស់ដីតំបន់នេះ អាចមានលក្ខណៈជាការដាំឈើបែបផែនពាណិជ្ជកម្មវាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម ប្រសិនបើអនុវត្តវិធានការណ៍អភិរក្សបានត្រឹមត្រូវ។

**ចំណាត់ថ្នាក់ទី៤:** ដីសម្បទានតំបន់នេះ មានទីជំរាលចំណាត់ថ្នាក់ ២-៥ដឺក្រេ ចំនួន១៦៣២,៣ហិកតា ឬស្មើនឹង១៦,៣៤ភាគរយ នៃផ្ទៃដីសរុប ដីតំបន់នេះមានលក្ខណៈស្ទើររាបស្មើ មិនមានតំរូវការនៃការអភិរក្សទឹក និងដីទេ។ តាមទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ។ ការប្រើប្រាស់ដីតំបន់នេះ អាចប្រើប្រាស់សំរាប់កសិកម្ម និងព្រៃឈើ។

**ចំណាត់ថ្នាក់ទី៥:** ដីសម្បទានតំបន់នេះ មានទីជំរាលចំណាត់ថ្នាក់ ០-២ដឺក្រេ ចំនួន ៨២៣៨,០ហិកតា ឬស្មើនឹង៨២,៥០ភាគរយ នៃផ្ទៃដីសរុប ជាដីរាបស្មើ។ ផ្អែកលើទស្សនៈនៃការ អភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ។ ដីតំបន់នេះ អាចប្រើប្រាស់សំរាប់ដំណាំស្រូវ និងដំណាំកសិកម្ម និងព្រៃឈើ។

**១២៨.** នៅក្នុងរយៈពេលនៃការសិក្សាអង្កេតអំពីលក្ខណៈអេកូឡូស៊ី ការយកសំណាកដីត្រូវបានធ្វើឡើងដោយផ្ទៀងផ្ទាត់ជាមួយនិងរបាយការណ៍របស់លោក D.Crocker ឆ្នាំ ១៩៦២-៦៣ ដើម្បីជាមូលដ្ឋានសំរាប់ធ្វើការប្រៀបធៀប។ តាមរយៈលទ្ធផលដែលទទួលបានជាក់ស្តែងបង្ហាញអោយឃើញថា ពុំមានការប្រែប្រួលជាពិសេសណាមួយបានកើតតាំងពីពេលនោះរហូតមកទល់បច្ចុប្បន្ននោះទេ។ ហើយម្យ៉ាងវិញទៀតប្រភេទដីមានលក្ខណៈឆ្លើយតបទៅនឹងប្រភេទនៃដំណុះដែលយើងសង្កេតឃើញនៅក្នុងតំបន់ដីសម្បទានផងដែរ។

Draft

១២៩. យោងតាមរបាយការណ៍របស់លោក D. Crocker ក្នុងឆ្នាំ ១៩៦២-៦៣ នៅក្នុងរយៈពេលនៃការធ្វើអង្កេតលើលក្ខណៈអេកូឡូស៊ីដែលបានប្រព្រឹត្តទៅពេលថ្មីៗនេះ ភាគច្រើននៃប្រភេទរបស់ដីនៅក្នុងតំបន់ដីសម្បទានបានរក្សាទុកនូវសភាពដើមដោយគ្មានអ្វីប្រែប្រួលគួរអោយកត់សំគាល់ឡើយ បើប្រៀបធៀបជាមួយនឹងរបាយការណ៍របស់លោក D. Crocker លើកលែងតែការផ្លាស់ប្តូរមួយផ្នែកតូចប៉ុណ្ណោះដែលកើតមានជាពិសេសចំពោះដីល្បាប់។ ការប្រែប្រួលនេះអាចធ្វើការបកស្រាយបានដោយយោងទៅលើមូលហេតុនៃទឹកជំនន់ទៅតាមរដូវនៅក្នុងតំបន់ទំនាបរបស់ដីសម្បទាន។ យោងទៅលើលក្ខណៈដើមនិងលក្ខណៈនៃឋានលេខា យើងអាចបែងចែកប្រភេទដីដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម :

| ល.រ | ប្រភេទដី | ទំហំផ្ទៃដី (ហិកតា) | ភាគរយ (%) |
|---|---|---|---|
| ១ | Acid Lithosols | ៥៦០.២ | ៥.៦១ |
| ២ | Grey hydromorphics | ១៦៣០.៨ | ១៦.៣៣ |
| ៣ | Planosols | ៧៧៩៤.០ | ៧៨.០៦ |
| **សរុប** | | **៩៩៨៥** | **១០០** |

- **Acid Lithosols:** ដីប្រភេទនេះមានចំនួន ៥៦០.២ហិកតា ឬស្មើនឹង ៥.៦១ភាគរយ ភាគច្រើននៃផ្ទៃដីនេះសង្កេតឃើញមាននៅផ្នែកខាងជើង និងខាងកើតនៃដីសម្បទាន។

- **Grey Hydromorphics:** ដីប្រភេទនេះមានចំនួន ១៦៣០.៨ហិកតា ឬស្មើនឹង១៦.៣៣ភាគរយ ផ្ទៃដីនេះសង្កេតឃើញមាននៅផ្នែកខាងកើតឈាងខាងត្បូងនៃដីសម្បទាន។

- **Planosols:** ដីប្រភេទនេះមានចំនួន ៧៧៩៤.០ហិកតា ឬស្មើនឹង ៧៨.០៦ភាគរយ និងទីតាំងនៃដីនេះសង្កេតឃើញមាននៅស្ទើរតែពាសពេញនៃដីសម្បទាន។

## ៤-១-៣ សារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់ដី

### ៤-១-៣-១ សារព័ន្ធរុក្ខជាតិ

១៣០. សារព័ន្ធព្រៃឈើដែលគ្របដណ្តប់នៅក្នុងតំបន់ព្រៃសម្បទាន បានកើតមានឡើងដោយសារប្រភេទព្រៃសំខាន់ចំនួន ៣ គឺព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ។ ដើមកំណើតនៃប្រភេទព្រៃនេះអាស្រ័យទៅនឹងកត្តាអាកាសធាតុ លក្ខណៈភូមិសាស្ត្រ និងសណ្ឋានដី រួមជាមួយសមាសភាពនៃប្រភេទឈើ ហើយ ប្រភេទព្រៃនេះ បានកើតឡើងដោយសារអនុប្រភេទជាច្រើនទៀត។ ឯកសារយោងដែលបានប្រើនៅ

Draft

ក្នុងរយៈពេលនៃការសិក្សា និងអង្កេតដែលធ្វើឡើងនៅក្នុងតំបន់ព្រៃសម្បទាន គឺជារូបភាពផ្កាយរណប ឆ្នាំ២០០៦របស់រដ្ឋបាលព្រៃឈើ។ នៅក្នុងរយៈពេលនៃការវាយ តំលៃជាក់ស្តែងអំពីតំលៃអេកូឡូស៊ី និង តំលៃពាណិជ្ជកម្មរបស់ព្រៃបានបញ្ជាក់ថា នៅទូទាំងតំបន់សម្បទាន ស្ថានភាពអេកូឡូស៊ីមានការប្រែប្រួល គួរអោយកត់សំគាល់ ដោយសារវត្តមានឈើដែលមានតំលៃពាណិជ្ជកម្មនៅមានសេសសល់តិចតួច ពីព្រោះ ស្ថានភាពព្រៃតំបន់នោះទទួលរងនូវការធ្វើអាជីវកម្ម និងការកាប់ឈើយកដីធ្វើជាកម្មសិទ្ធិពីសំណាក់ប្រជាជន ពីព្រោះជាប្រភេទព្រៃល្បោះរេចរិលដែលធ្វើ អោយតំបន់នេះប្រែក្លាយជាព្រៃគ្មានគុណភាពសេដ្ឋកិច្ច ឬជាតំបន់ ព្រៃរេចរិល។

**១៣១.** បញ្ហាដង់ស៊ីតេទាបនៃតំបន់ព្រៃ ជាពិសេសចំពោះព្រៃល្បោះនៃតំបន់ដីសម្បទានកើតមានឡើងដោយសារ កត្តាសកម្មភាពរបស់មនុស្សដូចជាៈ ការកាប់រានយកដីធ្វើកម្មសិទ្ធតាមការ ធ្វើសំភាសន៍ជាមួយប្រជាជននៅតំបន់ នោះ និងតាមរយៈការចុះអង្កេតដោយផ្ទាល់បានអោយដឹងថា ស្ថានភាពព្រៃក្នុងតំបន់នេះពុំមានវត្តមានឈើដែល មានតំលៃពាណិជ្ជកម្មនៅសេសសល់ច្រើនទេ។ នៅរដូវប្រាំងព្រៃក្នុង តំបន់នេះតែងត្រូវភ្លើងឆេះ ជាពិសេសនៅ តាមដងផ្លូវដោយសារមានសកម្មភាពកាប់ព្រៃ និងដុតបំផ្លាញយកដីធ្វើជាកម្មសិទ្ធិ។

### ៤-១-៣-២ លំនាំនៃការប្រើប្រាស់ដី

**១៣២.** ជាច្រើនជំនាន់មកហើយរាល់សកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រទេសមួយផ្នែកធំ គឺផ្អែកលើកសិកម្ម ដែលបានប្រមូលផ្តុំនៅជុំវិញតំបន់ទំនាបទន្លេមេគង្គ។ ដំណាំកសិកម្មដែលមានគឺៈ ស្រូវ កៅស៊ូ សណ្តែក កប្បាស ពោត អំពៅ ម្នាស់ និងបន្លែផ្សេងៗទៀត។ ប៉ុន្តែថ្មីៗនេះសង្កេតឃើញមានការរីកដុះដាលនូវចលនា នៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្មជាច្រើន ដែលជាទិសដៅរបស់ រាជរដ្ឋាភិបាលនៅក្នុងការកាត់បន្ថយភាពក្រីក្រជនបទ តាមរយៈការទាក់ទាញវិនិយោគិនអោយធ្វើការវិនិយោគ នៅក្នុងវិស័យកសិកម្ម។

**១៣៣.** គួរកត់សំគាល់ផងដែរថា ការផ្លាស់ប្តូរនូវលំនាំនៃការប្រើប្រាស់ដីនៅក្នុងប្រទេសកម្ពុជាគឺកើតមាន ឡើងដោយសារហាយនភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ក្នុងរយៈពេលនៃបណ្តាឆ្នាំដែលសង្គ្រាមស៊ីវិល បានអូសបន្លាយរ៉ាំរ៉ៃក្នុងនោះផ្ទៃដីមួយភាគធំត្រូវបានបោះបង់ចោល ហើយបន្ទាប់មកក៏ក្លាយទៅជាដីដែលគ្មាន ជីជាតិ។ គ្រោះថ្នាក់ជាបន្តបន្ទាប់ដែលកើតមានឡើងដោយមិនអាចទាយទុកបាននៃឆ្នាំមហន្តរាយធម្មជាតិ បានជំរុញអោយមានការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជនបទ ឆ្ពោះទៅតំបន់ដីខ្ពស់ដូចជាតំបន់ព្រៃឈើ ជាដើមដែលជាជំរើសតែមួយគត់របស់ពួកគាត់ សំរាប់ប្តូរជាមួយនឹងវិធានការណ៍នៃការបន្តរស់នៅ។ ជាលទ្ធផល

Draft

បាតុភាពនេះបាននាំមកនូវកំណើននៃសម្ពាធទៅលើធនធានព្រៃឈើ ហើយនិងរីកដាលបន្តិចម្តងៗឆ្ពោះទៅរកតំបន់ភ្នំដោយសារការធ្លាក់នូវធនធានព្រៃឈើនៅក្នុងតំបន់ទំនាប ។

**១៣៤.** នៅក្នុងបរិបទនៃការរក្សាទឹកទុក ព្រៃឈើមានពហុមុខងារអេកូឡូស៊ីសំខាន់សំរាប់រុក្ខជាតិក្នុងការការពារ និងទប់ស្កាត់ការហូរច្រោះដី ដំណុះខ្សាច់នៅតាមបាតស្ទឹង ប្រភពទឹកនានា និងទឹកជំនន់នៅក្នុងតំបន់ទំនាប ។ អាស្រ័យហេតុនេះ តំបន់ដែលងាយរងការប៉ះទង្គិចមួយចំនួនដូចជា តំបន់រណបរបស់ប្រភពទឹកមិនចាំសំរាប់យកទៅប្រើប្រាស់ដើម្បីការអភិវឌ្ឍន៍កសិកម្មនោះទេ ពីព្រោះថាការប្រើប្រាស់នេះវាអាចនឹងនាំមកនូវការខូចខាត និងបាត់បង់ដីយ៉ាងលឿន ។

**១៣៥.** តាមការសង្កេតដោយរហ័សរបស់ក្រុមស្រាវជ្រាវបានបង្ហាញថា ជាទូទៅប្រភេទដីនៅតំបន់សម្បទានជាប្រភេទដីខ្សាច់ក្រម៉ៅ និងប្រផេះនៅតំបន់ជិតមាត់ទឹកនិងបាតអូរ ដីល្បាយខ្សាច់ មានថ្មផុសដោយកន្លែង ជាពិសេសតាមដងអូរ ដីឥដ្ឋក្រម៉ៅដោយកន្លែងដែលជាប្រភេទដីមានជីជាតិមធ្យមសំរាប់ដំណាំកសិ-ឧស្សាហកម្ម (ឧបសម្ព័ន្ធ១ ផែនទី១-៣) ។ ដីនៅតាមប្រភេទព្រៃល្បោះជាដីល្បាយខ្សាច់ សង្កេតឃើញមាន ភ្លើងឆេះព្រៃក្នុងដីព្រៃល្បោះព្រោះរចនាសម្ព័ន្ធថ្នាក់ក្រោមជាប្រភេទស្មៅ ស្មៅព្រិច និងកូនឈើតូចៗ។ ក្រុមការងារបានសង្កេតឃើញថាក្នុងតំបន់ដី សម្បទាននេះមានឈើពាណិជ្ជកម្មនៅសេសសល់តិចតួចណាស់ ។

Draft

### ៤-១-៤ ទឹកស្រទាប់លើ និងគុណភាពទឹក

**១៣៦. ទឹកស្រទាប់លើៈ** នៅតំបន់ដីសម្បទាននេះមិនសូវសម្បូរណ៍ប្រភពទឹកស្រទាប់លើច្រើនទេ ។ ប្រជាជននៅតំបន់នោះបានជីកអណ្តូងសំរាប់ស្តុកទឹកប្រើប្រាស់នៅរដូវប្រាំងក្បែរភូមិនិងនៅក្នុងភូមិ ។ តាមការពិនិត្យជាក់ស្តែងលើទីវាលបានសង្កេតឃើញថាអ្នកភូមិនៅតំបន់នោះប្រើប្រាស់ទឹកក្រោមដីដោយប្រើអណ្តូងស្នប់ កន្លែងខ្លះទៀតបានប្រើប្រាស់ទឹកស្រះ ។ ប៉ុន្តែតាមរយៈការពិនិត្យលើផែនទីប្រើប្រាស់ដី និងគំរបព្រៃ បង្ហាញថា មានប្រព័ន្ធអូរសំខាន់មាន០៤ខ្សែប៉ុណ្ណោះនៅរដូវវស្សា គឺអូរកោដូន្តិ អូរសំរោង អូរព្រះធាតុនិងស្ទឹងគ្រាំងក្រាង ។ ដោយហេតុថាដីសម្បទាននេះស្ថិតនៅឆ្ងាយពីតំបន់ឧស្សាហកម្ម ដូច្នេះ គុណភាពទឹកស្រទាប់លើក្នុងតំបន់នេះមិនទាន់ទទួលរងការបំពុលដោយជាតិគីមីនៅឡើយទេ ហើយប្រជាជននៅក្នុងតំបន់នោះបានប្រើប្រាស់ទឹក ពីប្រភពទាំងនោះទៀតផងនៅរដូវវស្សាដើម្បីធ្វើស្រែ និងប្រើប្រាស់ ។

**១៣៧. បទដ្ឋាននៃគុណភាពទឹកៈ** ប្រទេសនិមួយៗតែងមានបទដ្ឋានគុណភាពទឹកផ្សេងៗគ្នា ដោយឡែក ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ បទដ្ឋានគុណភាពទឹកអាចមិនដូចគ្នាទៅនឹងបទដ្ឋានអន្តរជាតិទេ (មើលឧបសម្ព័ន្ធ ៥-៥ *សេចក្តីណែនាំ របស់អង្គការសុខភាពពិភពលោក ស្តីពីបទដ្ឋានគុណភាពទឹកសំរាប់ការប្រើប្រាស់ផ្សេងៗ* ។

ដូច្នេះដើម្បី ធានាដល់ការប្រើប្រាស់ទឹកនៅក្នុងតំបន់គំរោងចាំបាច់ត្រូវវិភាគ ដោយបទដ្ឋានគុណភាពទឹករបស់ក្រសួងបរិស្ថានជាបទដ្ឋានគំរូ ( *បទដ្ឋានគុណភាពទឹករបស់ក្រសួងបរិស្ថាន* មានភ្ជាប់ក្នុង ឧបសម្ព័ន្ធ ៥-៦) ។

១៣៨. **ប្រភពដែលអាចបង្កនៃភាពកខ្វក់ដល់ទឹក:** យោងតាមស្ថានភាពភូមិសាស្ត្ររបស់ដីសម្បទាន និងការអង្កេតជាក់ស្តែងនៅទីវាលបញ្ជាក់ថា ប្រភពដែលអាចបង្កអោយមានភាពកខ្វក់ដល់ទឹកអាចកើតមានឡើងនៅក្នុងករណីដែលដំណើរប្រតិបត្តិការដាំដុះមិនបានអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថានបានត្រឹមត្រូវ ។

១៣៩. **ការយកសំណាកទឹក និងការវិភាគ:** ក្រុមការងារបានយកសំណាកទឹកចំនួន ០២សំណាក កាលពីថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩ លើទីតាំងដែលមានចំណុចនិយាមកា (400303 1307481) និង (403974 1303046) ដើម្បីធ្វើការវិភាគអំពីលក្ខណៈគីមី ។ តាមរយៈការពិនិត្យទៅលើថាវរូបបន្ទរ (Parameters) ចំនួន២២ នៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានបង្ហាញថា កំរិតប៉ារ៉ាមែត្រមួយចំនួននៅ ក្នុងទឹកស្រទាប់លើនៅតំបន់ដីសម្បទានដែលបានយកសំណាកពីទឹកអូរមានបរិមាណទាបជាងបទដ្ឋានគុណភាពទឹក ដែលអាចអនុញ្ញាតិអោយបរិភោគបាន ។ ចំពោះបញ្ហាតុល្យភាពអ៊ីដ្រូសែន (pH = 6.48) មានកំរិតទាបជាងស្តង់ដារទឹកផឹកដែលជាប្រភេទអាស៊ីតខ្សោយ ។ ចំណែកឯរូបធាតុមួយចំនួនដូចជា នីកែល (14.26µg/l) កូបាល់ (<0.5µg/l) និងបារ៉ែត (<0.50µg/l) ។ ចំណែកការសិក្សាលើប៉ារ៉ាម៉ែត្រទាំង ២២នេះដដែលនៅក្នុងទឹកក្រោមដី ក៏បានបង្ហាញថា សារធាតុមួយចំនួនមាន បរិមាណទាបជាងកំរិតបទដ្ឋានគុណភាពសំរាប់ទឹកបរិភោគដែរ ។ ចំពោះបញ្ហាតុល្យភាពអ៊ីដ្រូសែន (pH =7.19) ស្ថិតក្នុងស្តង់ដារទឹកផឹកដែលជាប្រភេទអាស៊ីត ឬបាសខ្សោយ ។ ចំណែកឯរូបធាតុមួយចំនួនដូចជា នីកែល (50.11µg/l) កូបាល់ (<0.5µg/l) និងបារ៉ែត (0.50µg/l) ត្រូវបានពិនិត្យ ឃើញមានវត្តមាននៅក្នុងដែលជាធម្មតា រូបធាតុទាំងពីរនេះ ក៏ត្រូវបានពិនិត្យឃើញមានវត្តមាននៅក្នុងទឹកសម្រាប់បរិភោគដែរ ដូច្នេះមុននឹងយកទឹកទៅបរិភោគត្រូវប្រើធុងចម្រោះ ឬដាំឱ្យពុះទើបអាចជាការប្រសើរសំរាប់អនាម័យ និងសុខភាព ( ឧបសម្ព័ន្ធ៥-៧:លទ្ធផល វិភាគទឹកពីក្រសួងបរិស្ថាន) ។

## ៤-២ ធនធានអេកូឡូស៊ី

១៤០. តាមការអង្កេតអេកូឡូស៊ីនៅក្នុងតំបន់ស្នើសុំខាងលើបានបង្ហាញថា សារព័ន្ធរុក្ខជាតិនៅក្នុងតំបន់មានគំរូព្រៃសំខាន់ពីរគឺ ព្រៃល្បោះ និង ព្រៃពាក់កណ្តាលស្រោង ។ តាមការពិនិត្យអង្កេតដោយផ្ទាល់ និងការធ្វើសំភាសន៍ជាមួយ ក្រុមឧទ្យានុរក្ស នៅតំបន់នេះបានអោយដឹងថាធនធានព្រៃឈើមាននៅសេសសល់តិចតួចប៉ុណ្ណោះ លើកលែងតែនៅតាមភ្នំ ។ ជាក់ស្តែងចំពោះព្រៃតំបន់នេះ ទទួលរងនូវការកាប់បំផ្លាញមួយភាគធំតាមរយៈការ កាប់ឈើដើម្បីដុតធ្យូង កាប់ដកហូតនៅប្រភេទឈើដែលមានតំលៃពាណិជ្ជកម្ម និងប្រជាជនការចាប់ដីដើម្បីធ្វើស្រែ ចំការ ព្រមទាំងក្រុមហ៊ុនបានធ្វើការឈូសឆាយលើផ្ទៃដីនេះប្រមាណជា ១០% ទៅ ២០%

Draft

រួចហើយ ។ យោងតាមរូបភាពផ្កាយរណប ដែលបកស្រាយដោយ (FA GIS Dataset 2006) (ឧបសម្ព័ន្ធ ១-៧) បានបង្ហាញថាស្ថានភាព គំរបព្រៃ និងការប្រើប្រាស់ដីនៅក្នុងតំបន់ដីស្នើមានដូចក្នុងតារាងខាងក្រោម:

| ល.រ | គំរបព្រៃ | ផ្ទៃដី (ហិកតា) | ផ្ទៃដី (%) |
|---|---|---|---|
| ១ | ព្រៃស្រោង | ៧៩២.៩ | ៧.៩៤ |
| ២ | ព្រៃពាក់កណ្តាលស្រោង | ៣៣១.៣ | ៣.៣២ |
| ៣ | ព្រៃល្បោះ | ៨៨៥៤ | ៨៨.៦៧ |
| ៤ | ដីគ្មានគំរបព្រៃ | ៦.៩ | ០.០៧ |
| សរុប | | ៩៩៨៥ | ១០០ |

**១៤១.** តាមការអង្កេតលក្ខណៈអេកូឡូស៊ីបានបង្ហាញថា នៅក្នុងដែនព្រៃស្នើសុំនេះមានឈើដែលមានអង្កត់ផ្ចិតធំជាង ៥០ស.ម ហើយតាមរយៈផែនទីគំរបព្រៃ និងការប្រើប្រាស់ដីបានបង្ហាញថា តំបន់ស្នើសុំនេះគ្របដណ្តប់ដោយព្រៃល្បោះ ៨៨.៦៧% ព្រៃពាក់កណ្តាលស្រោង ៣.៣២% ព្រៃស្រោង ៧.៩៤% ជាសរុបព្រៃក្នុងតំបន់ស្នើសុំនេះមាន ៩៩.៩៣% នៃផ្ទៃដីសរុប ។ ឈើដែលមានតំលៃពាណិជ្ជកម្ម មានបង្គួរ ជាពិសេសនៅតំបន់ដែលឆ្ងាយពីភូមិ និងនៅលើភ្នំ ។ ឈើភាគច្រើនស្ថិតក្នុង អំបូរ *Dipterocarpaceae* ដែលជាមិនមានឈើតំលៃពាណិជ្ជកម្មនៅសេសសល់ទៀតទេ នៅមានតែប្រភេទ ឈើសំរាប់ធ្វើសរសផ្ទះ ក្តារ និងមានតែឈើតូចៗ ដែលទើប និងដុះឡើងវិញតែប៉ុណ្ណោះ ។ ដោយឡែកចំពោះ ប្រភេទឈើដែលជិតផុតពូជមួយចំនួនដូចជា: ប្រាំតំឡឹង *(Combretaceae)* អង្កត់ខ្មៅ *(Ebenaceae)* បេង *(Caesalpiniaceae)* នាងនួន *(Papilionaceae)* ឈើខ្មៅ *(Ebenaceae)* ត្រយឹង *(Ebenaceae)* តាត្រាវ *(Loganiaceae)* គ្រើល *(Anacardiaceae)* និងធ្នង់ *(Papilionaceae)* និងក្រញូងយើងពុំសង្កេតឃើញមានវត្តមាននៅក្នុងតំបន់នោះទេ ។ ប្រភេទឈើដែលប្រទះឃើញមានដូចជា:

| **ឈ្មោះក្នុងស្រុក** | **ឈ្មោះវិទ្យាសាស្ត្រ** | **ឈ្មោះអំបូរ** |
|---|---|---|
| ក្រឡាញ់ | *Dialium cochinchinensis* | *Caesalpiniaceae* |
| ត្រសេក | *Peltophorum ferrugineum* | *Caesalpiniaceae* |
| រាំងភ្នំ | *Pentacme suavis* | *Dipterocarpacees* |
| ពពេល | *Shorea cochinchinensis* | *Dipterocarpacees* |
| ផ្ចឿក | *Shorea obtusa* | *Dipterocarpacees* |



Draft

| | | |
|---|---|---|
| កកោះ | *Sindora cochinchinensis* | *Caesalpiniaceae* |
| ឈ្លីក | *Terminalia tomentosa* | *Combretaceae* |
| ពពូល | *Vitex sp* | *Verbenaceae* |
| សុក្រម | *Xylia dolabriformis* | *Mimosaceae* |
| ក្ទាវ | *Adina cordifolia* | *Dipterocarpaceae* |
| ត្បែង | *Diptercapus obtusifolius* | *Dipterocarpaceae* |
| ត្រាច | *Dipterocarpus intricatus* | *Dipterocarpaceae* |
| ត្បូង | *Dipterocarpus tuberculatus* | *Dipterocarpaceae* |
| ស្រូល | *Poducarpus cupressina* | *Podocarpaceae* |
| ច្រម៉ាស់ | *Vatica astrotricha* | *Dipterocarpaceae* |
| បង្គៅ | *Aglaia gigantia* | *Meliaceae* |
| កណ្តោល | *Careya sphaerica* | *Myrtaceae* |
| ព្រីង | *Eugenia sp.* | *Myrtaceae* |
| ព្រូស | *Garcinia ferrea* | *Guttiferes* |
| ត្រមូង | *Garcinia schomburghiana* | *Guttiferes* |
| ក្រាយ | *Kayea engeniafolia* | *Guttiferes* |
| ស្មាក្របី | *Knema corticosa* | *Myristicaceae* |
| ធ្លក | *Parinarium annamensis* | *Rosaceae* |
| ស្វាយព្រៃ | *Swintonia pierri* | *Anacardiaceae* |
| ធ្នីក | *Shorea obtusa* | *Dipterocarpaceae* |
| ឃ្លាស (ក្បៀស) | *Memecylon edule* | *Melastomaceae* |
| ល្បៀង | *Cratoxylum formosum subsp* | *Guttiferes* |
| តាឡាត់ | *Canarium album* | *Burseraceae* |
| ភ្លូបាត | *Dillenia hookeri* | *Dilleniaceae* |
| ញរព្រៃ (ញរធំ) | *Morinda tomenta* | *Rubiaceae* |
| ស្តៅ | *Azadirachta indica* | *Meliaceae* |
| កន្ទួតព្រៃ | *Phyllanthus emblica* | *Euphorbiaceae* |
| ពពាលខែ | *Alstonia scholaris* | *Apocynaceae* |

Draft

| | | |
|---|---|---|
| ភ្លៅនាង (ភ្លៅក្រមុំ) | *Cleistanthus tomentosa* | *Euphorviaceae* |
| ចំបក់ | *Irvingia malayana* | *Simaroubaceae* |

Source of families and scientific names: National priority tree species workshop, Cambodia Tree Seed Project/DANIDA, 2000.

**១៤២.** នៅក្នុងព្រៃល្បោះភាគច្រើនប្រទះឃើញឈើក្នុងអំបូរ *Dipterocarpacea, Mimosacea* និង *Caesalpini-aceae* ។ ព្រៃល្បោះមានកន្លែងខ្លះកំពុងទទួលរងនូវការគ្រៀវដើម កាប់រានព្រៃ និងដុតព្រៃយកដីដើម្បីធ្វើស្រែចំការនៅទីនោះ ។ ចំពោះប្រភេទឈើមានដូចជា ត្បែង ខ្លុង (ប្រភេទ លប់) ឈ្លីក ល្បៀង គ្រប់ទំ ស្នួល រាំង ត្បៀ នាងផ្អែម ស្គុំ កណ្តោល ជើងទា រកា ផ្ចឹក ពង្រ ចំបក់ សុក្រម ឈ្លីក ពពេល ស្រឡៅ ។ ចំណែកឯនៅក្នុងព្រៃពាក់កណ្តាលស្រោង មានឈើច្រើនប្រភេទដូចមានរាយឈ្មោះខាងលើតែ ក៏មានវត្តមានឈើក្នុងអំបូរ *Dipterocarpacea* ជាច្រើនដែរ ព្រោះជាអំបូរមានការលូតលាស់ លឿន និងងាយដុះ និងមានវត្តមាននៅក្នុងប្រភេទព្រៃទាំងបី ។ ដើមឈើទាំងនោះភាគច្រើនមានអង្កត់ផ្ចិតពី ៣០-៤៩ស.ម ទេប៉ុន្តែមានដើមឈើដែលមានអង្កត់ផ្ចិតធំជាង ៣០-៤៩ស.ម តិចតួចបំផុតក្នុងតំបន់នេះ ។ ក្រុមអង្កេតបានជួបប្រទេះឈើក្រៅលំដាប់ថ្នាក់ជាច្រើនទៀតដែល មិនមានឈ្មោះវិទ្យាសាស្ត្រដុះនៅក្នុង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ ។

**១៤៣.** តាមប្រភពព័ត៌មានដែលបានពីការអង្កេតដល់មូលដ្ឋានជាមួយប្រជាជនបានអោយដឹងថាៈ ស្ថានភាពព្រៃនេះបានទទួលរងការធ្វើអាជីវកម្មអានាធិបតេយ្យដោយប្រជាជននៅទីនោះ ដើម្បីយកដីធ្វើស្រែចំការ និងសង់លំនៅដ្ឋាន ។ បច្ចុប្បន្នមិនមានការធ្វើអាជីវកម្មកាប់ឈើយកធ្វើអុស និងយកមកប្រើប្រាស់ ពីសំណាក់ប្រជាជននៅក្នុងតំបន់នេះទេ ។ ក្រុមអង្កេតអេកូឡូស៊ីបានធ្វើការពិនិត្យទៅលើព្រៃ ០២ប្រភេទគឺៈ ព្រៃល្បោះ និងព្រៃពាក់កណ្តាលស្រោងហើយរុក្ខជាតិថ្នាក់ក្រោមមានកូនឈើតូចៗ ស្មៅ និងព្រិច ហើយមានសភាពស្ងួតខ្លាំងនៅរដូវប្រាំង និងមានភ្លើងឆេះ ។

**១៤៤.** តាមរយៈការគណនាចំនួនដើមឈើទៅតាមប្រភេទព្រៃល្បោះខាងលើបានបង្ហាញថា ក្នុងព្រៃល្បោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង ៥០សម ពុំសង្កេតឃើញមានវត្តមាននៅតំបន់នេះទេ ។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានពី ៦-៣២ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ៧ដើមក្នុង១ហិកតា ។ ដូច្នេះក្នុងដីព្រៃល្បោះ ៨៨៥៤ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានចំនួន ៦១៩៧៨ដើម ។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានពី ១២-៤២ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ២៥ដើមក្នុង១ហិកតា ។ ដូច្នេះក្នុងដីព្រៃល្បោះ ៨៨៥៤ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានចំនួន ២២១៣៥០ដើម ។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ៥-៩សម មានពី ២៥-

Draft

៧៦ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ៤៨ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃល្បោះ ៨៨៥៤ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៥-៩សម មានចំនួន ៤២៤៩៩២ដើម។ ស្ថានភាពគំរបព្រៃក្នុងតំបន់នេះជាមធ្យមមាន តែ ១៨ភាគរយ នៃផ្ទៃដីបានសិក្សាសរុបតែប៉ុណ្ណោះ (ឧបសម្ព័ន្ធ៤-តារាង១)។

១៤៥. តាមរយៈការគណនាចំនួនដើមឈើទៅតាមប្រភេទព្រៃពាក់កណ្តាលស្រោងខាងលើបានបង្ហាញថា ក្នុងព្រៃពាក់កណ្តាលស្រោងដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង ៥០សម ពុំសង្កេតឃើញមានវត្តមាននៅតំបន់នេះទេ។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានពី ១២-១៨ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ១៥ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃពាក់កណ្តាលស្រោង ៣៣១,៣ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានចំនួន ៤៩៧០ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានពី ១៩-២៤ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ២២ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃពាក់កណ្តាលស្រោង ៣៣១,៣ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានចំនួន ៧២៨៩ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ៥-៩សម មានពី ៣៥-៤៥ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ៤០ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃពាក់កណ្តាលស្រោង ៣៣១,៣ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៥-៩សម មានចំនួន ១៣២៥២ដើម។ ស្ថានភាពគំរបព្រៃក្នុងតំបន់នេះជាមធ្យមមានតែ ៣៤ភាគរយ នៃផ្ទៃដីបានសិក្សាសរុបតែប៉ុណ្ណោះ (ឧបសម្ព័ន្ធ៤-តារាង១)។

## ៤-៣ ធនធានបាយ៉ូម៉ាស (BIOMASS)

Draft

១៤៦. នៅក្នុងដីសម្បទាននេះមានឈើដែលមានអង្កត់ផ្ចិតត្រឹម ១០-៤៩ស.ម ហេតុនេះការគណនាធនធានជីវម៉ាស់គិតត្រឹម ឈើដែលមានអង្កត់ផ្ចិតចាប់ពី ១០-៤៩ស.ម។ នៅក្នុងព្រៃពាក់កណ្តាលស្រោងជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៤០-៤៩ស.ម មានពី ៧៩២៤-១៥៨៤៨គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ១១៨៨៦គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃពាក់កណ្តាលស្រោងចំនួន ៣៣១,៣ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៤០-៤៩ស.ម មានសរុបចំនួន ៣៩៣៧៨៣១,៨គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៣៩ស.ម មានពី ៨៩២៨-១១១៦០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ១០០៤៤គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃពាក់កណ្តាលស្រោងចំនួន ៣៣១,៣ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៣៩ស.ម មានសរុបចំនួន ៣៣២៧៥៧៧,២គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ ពី ២០-២៩ស.ម មានពី ៣៤៩៣-៤៩៩០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៤២៤២គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃពាក់កណ្តាលស្រោងចំនួន ៣៣១,៣ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ២០-២៩ស.ម មានសរុបចំនួន ១៤០៥៣៧៤,៦គ.ក្រ។ ជីវម៉ាស់ឈើដែលមាន

អង្កត់ផ្ចិតចាប់ពី ១០-១៩ស.ម មានពី ១៥៦០-១៨២០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ១៦៩០គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើ ផ្ទៃដីព្រៃពាក់កណ្ដាលស្រោងចំនួន ៣៣១,៣ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ១០-១៩ស.ម មានសរុបចំនួន ៥៥៩៨៩៧គ.ក្រ។ ជាសរុបឈើដែលមានអង្កត់ផ្ចិតពី ១០-៤៩សម ក្នុងព្រៃពាក់កណ្ដាលស្រោងគិតជាមធ្យមជីវៈម៉ាស ២៧៨៦១,៥គីឡូក្រាមក្នុង១ហិកតា ដូច្នេះក្នុងព្រៃពាក់កណ្ដាលស្រោង ៣៣១,៣ហិកតា ឈើដែលមានអង្កត់ផ្ចិត ១០-៤៩សម មានជីវៈម៉ាសសរុប ៩២៣០៥១៤,៩៥គីឡូក្រាម (៩២៣០,៥២តោន) ក្នុងកំរិតលំអៀងបូកឬដក ១០ភាគរយនៃចំនួនសរុបនេះ។

**១៤៧.** នៅក្នុងព្រៃល្បោះ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៤០-៤៩ស.ម មានពី ៣៩៦២-១៣៨៦៧គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៣០១៤,៥៧គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៤០-៤៩ស.ម មានសរុបចំនួន ២៦៦៩១០០២,៧៨គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៣០-៣៩ស.ម មានពី ៥៥៨០-៣០១៣២គ.ក្រ ក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៤៨៥២,១៧គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៣០-៣៩ស.ម មានសរុបចំនួន ៤២៩៦១១១៣,១៨គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ២០-២៩ស.ម មានពី ៩៩៨-៥៤៨៩គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៣២៥៤,៣៥គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ២០-២៩ស.ម មានសរុបចំនួន ២៨៨១៤០១៤,៩គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ១០-១៩ស.ម មានពី ៩១០-៤១៦០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ២២៧៧,៨៣គ.ក្រ ក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដី ព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ១០-១៩ស.ម មានសរុបចំនួន ២០១៦៧៩០៦,៨២គ.ក្រ។ ជាសរុបឈើដែលមានអង្កត់ផ្ចិតពី ១០-៤៩សម ក្នុងព្រៃល្បោះគិតជាមធ្យមជីវៈម៉ាស ១៣៣៩៨,៩គីឡូក្រាមក្នុង១ហិកតា ដូច្នេះក្នុងព្រៃល្បោះ ៨៨៥៤ហិកតា ឈើដែលមានអង្កត់ផ្ចិត ១០-៤៩សម មានជីវៈម៉ាសសរុប ១១៨៦៣៣៨៦០,៦គីឡូក្រាម (១១៨៦៣៣,៨៦តោន) ក្នុងកំរិតលំអៀងបូកឬដក ១០ភាគរយនៃចំនួនសរុបនេះ។ ជីវម៉ាសទាំងអស់ត្រូវបានគណនាក្នុងកំរិតលំអៀង ១០% ដោយសារ ឈើនៅក្នុងព្រៃមាន : ឈើប្រហោង ឈើមានមែកងាប់ និងឈើពុក ដែលមិនអាចប្រើការបាន ។ល។

**១៤៨.** នៅក្នុងព្រៃពាក់កណ្ដាលស្រោង ៣៣១,៣ហិកតា កំណើនជីវម៉ាស់របស់ឈើដែលមានអង្កត់ផ្ចិតធំជាង ១០ស.ម ក្នុងដីសម្បទាននេះមានចាប់ពី ១៩៣,៨៤-២១០,៦៤មេកាក្រាម ក្នុងរយៈ៥ឆ្នាំដំបូង (ពីឆ្នាំទី១ដល់៥) ចាប់ពី ២១៥,០៧-២៣៣,៧១មេកាក្រាម ក្នុងរយៈ៥ឆ្នាំបន្ទាប់ (ពីឆ្នាំទី៦ដល់១០) និងចាប់ពី

Draft

២៣៨,៦២-២៥៩,៨០ មេកាក្រាម ក្នុងរយៈ១៥ឆ្នាំក្រោយ។ កំណើនជីវម៉ាស់សរុបគិតចាប់ពីឆ្នាំទី ១ ដល់ឆ្នាំ ១៥ ស្មើនឹង ៣៣៧៦,៤៩មេកាក្រាម (ឧបសម្ព័ន្ធ ៤-តារាង៣) ។

**១៤៩.** នៅក្នុងព្រៃល្បោះ ៨៨៥៤ហិកតា កំណើនជីវម៉ាស់របស់ឈើដែលមានអង្កត់ផ្ចិតធំជាង ១០ស.ម ក្នុងដីសម្បទាននេះ មានចាប់ពី ២៨៤៧,២២-៣១៣០,៥៥មេកាក្រាម ក្នុងរយៈ៥ឆ្នាំដំបូង (ឆ្នាំទី១-ឆ្នាំទី៥) ចាប់ពី ៣២០៥,៦៨-៣៥២៤,៦៨មេកាក្រាមក្នុងរយៈ៥ឆ្នាំបន្ទាប់ (ឆ្នាំទី៦-ឆ្នាំទី១០) និងចាប់ពី ៣៦០៩,២៧ -៣៩៦៨,៤៤មេកាក្រាម ក្នុងរយៈ១៥ឆ្នាំក្រោយ។ កំណើនជីវម៉ាស់សរុបគិតចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី១៥ ស្មើនឹង ៥០៦៨៦,០៩មេកាក្រាម។ សង្កេតឃើញថាការលូតលាស់ជីវម៉ាស់នៅក្នុងព្រៃល្បោះ មានការលូតលាស់លឿនជាងការលូតលាស់ និងកើតកំណើនជីវម៉ាស់នៅក្នុងព្រៃស្រោងចំនួន ៤៧៣០៩,៦ មេកាក្រាម។ នេះគឺដោយសារស្ថានភាពលូតលាស់របស់ឈើនៅក្នុងព្រៃល្បោះមានសភាពដំណុះលឿនជាងឈើ នៅក្នុងព្រៃស្រោង (ឧបសម្ព័ន្ធ ៤-តារាង៣) ។

**១៥០.** ជាការពិតណាស់អន្តរកម្មរវាងជីវៈចំរុះនៅក្នុងតំបន់មួយ ស្តែងចេញនូវភាពខុសប្លែកគ្នាពីសារពាង្គកាយមួយទៅសារពាង្គកាយមួយទៀត។ វត្តមាននៃប្រភេទសត្វដែលរស់នៅក្នុងព្រៃក៏មានភាពខុសប្លែកពីគ្នាពីតំបន់មួយទៅតំបន់មួយដែរ ដោយអាស្រ័យលើលក្ខខណ្ឌចំណីអាហារ ទីជំរក និងមជ្ឈដ្ឋាននៃការរស់នៅ។ តាមរយៈដំណើរការអង្កេត (សំរ៉ែក ដានជើង និងលាមក) និងការសំភាសន៍ជាមួយប្រជាជនដែលរស់នៅក្បែរទីនោះបានអោយដឹងថា នៅក្នុងតំបន់ស្នើសុំនោះគេប្រទះឃើញមានវត្តមានសត្វឈ្លូស ស្វាអង្កត់ ជ្រូកព្រៃ ទន្សាយ កំប្រុក កង្ហែន ត្រកួត ពស់ នៅតិចបំផុតគឺមាននៅលើភ្នំតែប៉ុណ្ណោះ។ល។ តាមរយៈការសាកសួរប្រជាជនដែលរស់នៅតំបន់ដដែលនោះក៏បានអោយដឹងផងដែរថា ប្រភេទសត្វចតុប្បាទធំៗ លែងមានឃើញនៅក្នុងតំបន់នេះទៀតហើយ។

**១៥១.** ចំពោះសត្វស្លាបដែលក្រុមសិក្សាសង្កេតឃើញ ដោយបង្ហាញពីវត្តមានសត្វតាមរយៈ ដានជើង សំរ៉ែក និង លាមក សង្កេតឃើញមានដូចជា: មាន់ព្រៃ តុក ក្អែក ចាបទ្រូងលឿង ទទារ រលលក គ្រួចអឹត សារិកាកែវ។ល។ តាមរយៈការសាកសួរប្រជាជនដែលរស់នៅ ក្បែរតំបន់សម្បទាននេះបានអោយដឹងដែរថា មិនឃើញមានសត្វ ស្លាបធំៗទេ។ ភាពសំបូរបែបនៃវត្តមាន សត្វស្លាបទាំងនោះ បានដើរតួនាទីយ៉ាងសំខាន់សំរាប់ការពឹងប្រាស្រ័យ គ្នាទៅវិញទៅមករវាងជីវៈចំរុះនៅក្នុងតំបន់ ជាពិសេសចំពោះការពង្រាយ និងការបន្តពូជនៃប្រភេទរុក្ខជាតិពី តំបន់មួយទៅតំបន់មួយទៀត។

Draft

**១៥២.** ការថយចុះ ឬការបាត់បង់វត្ថុមានប្រភេទមួយពីក្នុងតំបន់ បង្ហាញអោយឃើញថាធម្មជាតិនៅក្នុងតំបន់នោះចាប់ផ្តើមមានការប្រែប្រួលទាក់ទងទៅនឹង ចំណីអាហារ ទីជំរក និងមជ្ឈដ្ឋាននៃការរស់នៅ ជាពិសេសគឺការឈ្លានពាន និងរំខានពីកត្តាខាងក្រៅ (ការបបាញ់ ការបំផ្លាញទីជំរក និងការបាត់បង់ប្រភពចំណីអាហារ) ដោយសកម្មភាពមនុស្ស ឬសកម្មភាពធម្មជាតិខ្លួនឯងផ្ទាល់។ ផ្ទុយទៅវិញ ក្នុងអំឡុងពេលនៃការធ្វើការសិក្សាស្រាវជ្រាវបានសបញ្ជាក់អោយឃើញថា ការកាប់រានដីព្រៃសំរាប់យកដីដាំដំណាំ និងទុកអោយកូនចៅបានធ្វើអោយប៉ះពាល់ដល់ទីជំរក ប្រភពចំណីអាហារ និងបរិស្ថានរស់នៅ របស់ជីវៈចំរុះនៅតំបន់នោះអាចឈានទៅរកការផុតពូជនៅថ្ងៃអនាគត។ មិនតែប៉ុណ្ណោះការធ្លាក់ចុះនូវធនធានជីវៈចំរុះ បានបង្ហាញពីការបាត់បង់និរន្ត ភាពរវាងការចិញ្ចឹមជីវិត និងបរិស្ថានក្នុងតំបន់ផងដែរ។

**១៥៣.** ដោយឡែកសកម្មភាពបបាញ់ស្ទើតែពុំសូវមានសកម្មភាពទេ។ តែទោះជាយ៉ាងនេះក្តី សកម្មភាពបរបាញ់ខុសច្បាប់នៅតែកើតមានម្តងម្កាលជាលក្ខណៈទ្រង់ទ្រាយតូច ដូចជាការដាក់អន្ទាក់។

## ៤-៤ ការពិនិត្យនិងវាយតំលៃស្ថានភាពធនធានព្រៃឈើលើរូបភាពថតពីអាកាសដោយប្រើ Paramotor

**១៥៤.** ដើម្បីពិនិត្យ និងវាយតំលៃអំពីគំរបព្រៃ និងស្ថានភាពធនធានជាក់ស្តែងក្នុងពេលបច្ចុប្បន្ន ក្រុមការងារបានធ្វើការហោះហើរដោយប្រើឧបករណ៍ Paramotor ដើម្បីថតយករូបពិតពីអាកាស ហើយធ្វើការប្រៀបធៀបជាមួយនឹងរូបភាពប្រើប្រាស់ដីធ្លី និងគំរបព្រៃឆ្នាំ២០០២ និងការធ្វើអង្កេតអេកូឡូស៊ីជាក់ស្តែងនៅលើទីវាល។ ការហោះហើរតាមគន្លងដូចមានបង្ហាញក្នុងផែនទីវិស្សុតកម្មគន្លងហោះហើរ និងទីតាំងរូបថត (ឧបសម្ព័ន្ធ៧-១) បានធ្វើឡើងនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៩ ហើយបានថតយករូបភាពដែលមាន Format: Geo_tif និងកំរិតភាពច្បាស់សំរាប់វត្ថុមានទំហំពី៣០ស.មឡើង ដោយថតជាមួយនឹងប្រព័ន្ធកូអរដោនេនិយាមកា Datum: WGS-84 និង Spheroid: WGS-84 ស្ថិតក្នុងរយៈកំពស់៧០០ម៉ែត្រ។ នៅលើគន្លងហោះហើរចំងាយ ១៦គ.ម ក្រុមការងារបានថតយករូបភាពចំនួន១៦កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបចំនួន១៤៣៣ហិកតា ឬស្មើនឹង១៤.៣៥ភាគរយនៃផ្ទៃដីសម្បទានទាំងមូល។ ក្រៅពីរូបភាពដែលមាន Geo-Reference ក្រុមហោះហើរបានថតយករូបភាព Eye-View (ជារូបភាពដែលគ្មាន Geo-Reference) ចំនួន០៤កន្លែងទៀត ដែលមានទីតាំងដូចបានបង្ហាញក្នុងផែនទីវិសុត្សកម្ម (ឧបសម្ព័ន្ធ៧-២, ៣, ៤ និង៥)។

**១៥៥.** ដើម្បីសិក្សាវាយតំលៃលំអិត យើងបានជ្រើសរើសយក១១ចំណុច (Photo Index:A, B, C, D, E, F, G, H, I, J and K) មកពង្រីកក្នុងមាត្រដ្ឋាន ១:៣០០០ (ឧបសម្ព័ន្ធ ៧-៦ ៧-៧ ដល់ ៧-១៦)។ ចំណែកឯ រូបថតចំនួន០៥ចំណុច ទៀតមិនអាចធ្វើការបកស្រាយទាន់ ដោយសារត្រូវការពេលវេលានិងធនធាន

Draft

ច្រើនដើម្បីធ្វើអោយរូបថតទាំងនេះមាន Geo-Reference ប៉ុន្តែរូបភាពទាំងនេះអាចបកស្រាយជូនលំអិតបាននៅពេលក្រោយទៅតាមការចាំបាច់ ។

**១៥៦.** តាមរយៈការសិក្សាលំអិតទៅលើរូបភាព Photo-Index-F និងរូបភាព Eye_View3 និង 4 ទៅលើស្ថានភាពនៃការប្រើប្រាស់ដីក្នុងតំបន់ដែនសម្បទានបង្ហាញថា មានដីស្រែចំការរបស់ប្រជាជនមូលដ្ឋានដោយកន្លែងដែលនៅផ្នែកខាងត្បូងនៃដែនដីដែលស្នើសុំ ។ តាមការដែលជួបសន្ទនា ពិភាក្សាពិគ្រោះជាមួយប្រជាពលរដ្ឋនៅទីនោះបានបញ្ជាក់អោយដឹងថា នៅក្នុងតំបន់ដូចបានរៀបរាប់នេះពិតជាមានដីស្រែចំការរបស់ពួកគាត់មែនគឺមានទាំងនៅផ្នែកខាងត្បូង និងខាងជើងផងដែរ ។ ក្រៅពីការសិក្សាទៅលើស្ថានភាពនៃការប្រើប្រាស់ដីក្រុមការងារក៏បានចាប់អារម្មណ៍ទៅលើបញ្ហាការកាប់ព្រៃឈើយ៉ាងអាណាធិប្បតេយ្យ ដែលដឹកចេញតាមផ្លូវរទេះដែលមាននៅក្នុងដែនដីស្នើសុំនេះដែរ ។

**១៥៧.** តាមការពិនិត្យមើលលើរូបភាពទាំងនេះបានឱ្យឃើញថាមានប្រភពទឹកស្រទាប់លើច្រើនបង្គួរ ដូចជាស្ទឹង និងដងអូរនានា ។ តែដងអូមួយចំនួនត្រូវបានរីងហួតអស់នៅរដូវប្រាំង លើកលែងតែអូធំៗដូចជា អូរព្រះធាតុស្ទឹងតាំងក្រាំង គឺមានទឹកជាប្រចាំពេញ១ឆ្នាំ ដែលហូរចាក់ពីត្បូងទៅជើងហើយបន្តចូលទៅស្ទឹងព្រែកត្នោត ។ តាមការសង្កេត និងការសាកសួរពីប្រជាជន គឺពួកគាត់មួយចំនួនបានប្រើប្រាស់នូវទឹកទាំងនោះផងដែរ ។

Draft

**១៥៨.** តាមរយៈការសិក្សាអំពីស្ថានភាពប្រើប្រាស់ដី (តាមរយៈការជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុកឱរ៉ាល់) បានអោយដឹងថា ការផ្តល់ដីសម្បទាននៅក្នុងតំបន់នេះ បានបណ្តាលអោយប៉ះពាល់ដល់លទ្ធភាពប្រើប្រាស់ផល-អនុផលព្រៃឈើ របស់ប្រជាជននៅក្នុងឃុំសង្កែសាទប និងឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ។ ពួកគាត់ (អ្នកភូមិនៅក្នុង ឃុំ) មានដីស្រែ-ចំការ កន្លែងទីសក្ការៈ និងព្រៃសហគមន៍ដែលស្ថិតក្នុងទីតាំងដែលក្រុមហ៊ុនបានស្នើសុំ ។

## ៤-៥ ធនធានសង្គម និងសេដ្ឋកិច្ច

**១៥៩.** លទ្ធផលនៃការធ្វើ PRA មានបង្ហាញនៅទំព័រ ១២៣-១៣៧ (កំណត់ហេតុ និងរបាយការណ៍សង្ខេបស្តីពីការពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ និងសហគមន៍ពាក់ព័ន្ធ លើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម) ។

## ៤-៦ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

**១៦០.** ក្រៅពីក្នុងទីរួមខេត្ត ដីដែលនៅតាមសងខាងបណ្តោយផ្លូវជាតិភាគច្រើនគឺជនបទ ។ ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចក្នុងតំបន់នេះមានលក្ខណៈខុសៗគ្នាទៅតាមទីប្រជុំជន ខេត្ត ស្រុក និងជនបទ ។ ចំណែកឯ ប្រជាជន

ឃុំត្រពាំងជោ និងឃុំសង្កែសាទប ស្រុកឱរ៉ាល់ ក្រៅពីការប្រកបរបរធ្វើស្រែ រុករកផល-អនុផលព្រៃឈើ និងការចិញ្ចឹមសត្វ ក្រោយពីប្រមូលផលស្រូវរួច មានគ្រួសារខ្លះប្រកបរបរលក់ដូរបន្តិចបន្តួចតាមដងផ្លូវលេខ៥២ (ឧដុង-ឱរ៉ាល់) និងផ្លូវលេខ៤៤ (ច្បារមន-ឱរ៉ាល់) និងផ្លូវលំក្នុងឃុំ សម្រាប់បំរើតម្រូវការក្នុងភូមិ-ឃុំ និងអ្នកដំណើរមួយចំនួន ហើយមានគ្រួសារខ្លះបានធ្វើការ ដាំដំណាំ និងបន្លែបង្កាបន្តិចបន្តួចសម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសារ និងអាចលក់ដូរផង។

**១៦១.** តាមរយៈការចុះសិក្សាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅទីនោះ ប្រភពចំណូលសំខាន់របស់ពួកគាត់គឺអាស្រ័យលើមុខរបរធ្វើស្រែចំការ និងកាប់អុសម៉ែត្រ និងដុតធ្យូង (ដែលមួយខែៗ គ្រួសារនិមួយៗអាចរកចំណូលបានចន្លោះពី ២០០០០០-៦០០០០០រៀល គ្រួសារនិមួយៗមានឡធ្យូងពី១-៥ឡ ហើយឡនិមួយៗប្រើប្រាស់ឈើអុសចាប់ ពី៥-១០រទេះ(គោយន្ត)។ ចំណែកការធ្វើស្រែចំការវិញគឺសំរាប់តែទុកហូបនៅក្នុងគ្រួសារតែប៉ុណ្ណោះ ដែលក្នុង មួយហិកតាអាចទទួលបានទិន្នផល១-២,៥តោន ហើយស្រូវមួយគីឡូក្រាមលក់បានតំលៃ៨០០-១៥០០រៀល) ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ជាក់ស្តែងប្រជាពលរដ្ឋមានលទ្ធភាពអាចចិញ្ចឹមគោប្រមាណជា៨០%នៃចំនួន ប្រជាជនសរុបតាមភូមិនិមួយៗ ក្នុងនោះចំនួន៩០%បានចិញ្ចឹមគោពី៣-៥ក្បាល និងប្រមាជា១០%បានចិញ្ចឹម គោពី១០-២០ក្បាល។ ជាទូទៅការចិញ្ចឹមគោរបស់ពួកគាត់គឺ មិន ត្រឹមតែសម្រាប់ការប្រើប្រាស់ជាមធ្យោបាយ អូសទាញក្នុងការធ្វើស្រែចំការ និងចូលព្រៃដឹកឈើប៉ុណ្ណោះទេ ពួកគាត់ចិញ្ចឹមសំរាប់លក់ដូរផងនិងទុកគ្រាន់ ដោះស្រាយនៅពេលមានគ្រោះអាសន្នអន់ក្រផង។ តែក៏មានគ្រួសារមួយចំនួនពុំមានស្បៀងអាហារហូបគ្រប់ គ្រាន់ ដែលមានគ្រួសារខ្លះខ្វះខាតស្បៀងរហូតដល់ទៅ ២-៣ ខែឯណោះ។

**១៦២.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនិមួយៗ។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អត្រានៃភាពក្រីក្រនៅក្នុងខេត្តកំពង់ស្ពឺមាន: ១៨,២០ភាគរយ (១០៥,៣ពាន់) លើចំនួនប្រជាជនសរុប ៦៩០៩៦៣នាក់ ក្នុងនោះមាន ៦៤១៦៣០នាក់ ស្មើនឹង ៩៣ភាគរយរស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀង អង្គការសហប្រជាជាតិឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤)។ ចំនួនអ្នកមិនចេះអក្សរនៅក្នុងខេត្តកំពង់ស្ពឺទាំងមូលមានចំនួន ៨២៨០៦នាក។

**១៦៣.** គួរបញ្ជាក់ថា លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល) នៅក្នុងសហគមន៍ជនបទទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀបធៀបជាមួយនឹងគ្រួសារសហគមន៍នៅក្នុងតំបន់ដទៃទៀតរបស់ប្រទេសកម្ពុជា។ ការសិក្សាបានបង្ហាញអោយឃើញថាអ្នកភូមិក្នុង ឃុំត្រពាំងជោ និងឃុំសង្កែសាទប ស្រុកឱរ៉ាល់ ទាំងអស់ពុំបានទទួលការផ្គត់ផ្គង់អគ្គិសនីជាមូលដ្ឋាន

Draft

ទេ។ ចំពោះ បណ្តាញអគ្គិសនីនៅក្នុងតំបន់នោះគឺពុំទាន់មាននៅឡើយ គឺមានត្រឹមតែការប្រើប្រាស់ម៉ាស៊ីនភ្លើងជាលក្ខណៈ គ្រួសារតិចតួច ការប្រើប្រាស់ភ្លើងអាគុយប្រមាណជា ៥១.៣៧% និងចំនួន ៤៨.៦៣%ទៀតនៅប្រើចង្កៀង ប្រេងកាតនៅឡើយ សម្រាប់បំភ្លឺនៅពេលយប់។ ចំណែកឯការចំអិនអាហារវិញគឺពួកគាត់ប្រើធ្យូង និងអុស ដែលរកបានពីព្រៃនៅក្បែរៗភូមិ និងមួយចំនួនទៀតមានលទ្ធភាពប្រើប្រាស់ចង្ក្រានហ្គាសតិចតួច ចំពោះគ្រួសារ ដែលមានជីវភាពធូរធា(នៅទីប្រជុំជនក្នុងស្រុក)។ ការប្រើប្រាស់ទឹកស្អាតក៏នៅមានការិតជាក់ស្តែង នៅក្នុង ភូមិនិមួយៗពួកគាត់ប្រើប្រាស់ ទឹកអណ្តូងលូជីកដោយដៃ (ភាគច្រើនឧបត្ថម្ភដោយអង្គការ ឡឺ្យ) និងខ្លះ ទៀតប្រើប្រាស់ អណ្តូងស្នប់ (មានតិចតួច) ដែលអណ្តូងទាំងនេះមិនទាន់អាចផ្គត់ផ្គង់តំរូវការបានងាយស្រួល នៅឡើយទេ (១០ ទៅ១៥គ្រួសារ/អណ្តូង)។ គួររំលឹកដែរថាមុនពេលមានអង្គការចូលមកអភិវឌ្ឍន៍ នៅក្នុង តំបន់នេះប្រជាជនជួបការលំបាក ខ្លាំងចំពោះបញ្ហាទឹកប្រើប្រាស់ ដោយការប្រឈមមុខនឹងការប្រើប្រាស់ទឹកស្ទឹង ស្រះទឹកអូរ ត្រពាំង និងប្រភពទឹកផ្សេងៗទៀតនៅក្នុងតំបន់នេះដែលមិនមានអនាម័យត្រឹមត្រូវ និងមានការ ប៉ះពាល់ខ្លាំងទៅលើសុខភាពប្រជាជន (តាមប្រសាសន៍តំណាងប្រជាជនក្នុងមូលដ្ឋាន)។

**១៦៤.** ការធ្វើដំណើរ និងដឹកជញ្ជូនភាគច្រើនគឺ ប្រើប្រាស់ផ្លូវលេខ៥២ (ទីប្រជុំជនស្រុកឧដុង-ស្រុកឱរ៉ាល់) និងផ្លូវលេខ៤៤ (ស្រុកច្បារមន-ស្រុកឱរ៉ាល់) និងផ្លូវលំតូចៗចេញពីភូមិមក (ទីប្រជុំជនភូមិដំបងវេញ- ឃុំត្រពាំងជោ) ដែលជាផ្លូវយ៉ាងសំខាន់ចូល ទៅក្នុងតំបន់ដីសម្បទាននេះ។ ចំពោះស្ថានភាពផ្លូវគមនាគមន៍ ក្នុងតំបន់នេះជាផ្លូវក្រាលក្រួសក្រហម ប៉ុន្តែ បានទទួលរងនូវការខូចខាត ដោយកន្លែងដែលបណ្តាលពីការដឹកជញ្ជូនលើសកំណត់ជារឿយៗ។ នៅរដូវប្រាំងផ្លូវ មានសភាពហុយខ្លាំង ចំណែកនៅរដូវវស្សាវិញផ្លូវមានសភាពរអិល និងមានដក់ទឹកដោយកន្លែង ហើយពួក គាត់ប្រើប្រាស់កង់ ម៉ូតូ និងរថយន្តជាមធ្យោបាយធ្វើដំណើរ ឬដោយថ្មើរជើងនៅក្នុងតំបន់។

**១៦៥.** ចំណែកវិស័យអប់រំវិញ នៅក្នុងភូមិដែលពាក់ព័ន្ធ យើងឃើញមានសាលាបឋមសិក្សាស្ទើរគ្រប់ភូមិ ដែលមានត្រឹមថ្នាក់ទី១ ដល់ទី៦ ដូចជាភូមិសំរោង ភូមិចំបក់ និងភូមិត្រាង ងាយស្រួលដល់ការរៀនសូត្រដល់សិស្សានុសិស្ស។ រីឯសិស្ស សាលាអនុវិទ្យាល័យ ឬវិទ្យាល័យ ត្រូវទៅបន្តការសិក្សានៅ ទីរួមស្រុកឱរ៉ាល់ ដែលមានចម្ងាយ ១៥-២៥គ.មពីភូមិ។

## ៤-៧ ធនធានសង្គម និងវប្បធម៌

**១៦៦.** ក្រុមការងារបានធ្វើការសិក្សាវាយតំលៃអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងតំបន់ដែលក្រុមហ៊ុន **អេច អិល អេច អេគ្រ៉ូខលឈ័រ (ខេមបូឌា) ខូអិលធីឌី** បានស្នើសុំដែលមានទីតាំងស្ថិតនៅឃុំត្រពាំងជោ និងឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ឃុំត្រពាំងជោមានភូមិចំនួន២៣ មានប្រជាជន

សរុបចំនួន ១.៩៧៣គ្រួសារ ស្មើនឹង ៩.៣៧០នាក់ (ស្រី៤.៩៥៦នាក់) ឃុំនេះមានភូមិចំនួន១០ដែលមានពាក់ព័ន្ធនឹង ទីតាំងដីដែលក្រុមហ៊ុនស្នើសុំ ចំណែកឯ ឃុំសង្កែសាទបមានភូមិចំនួន១៥ មានប្រជាជនសរុបចំនួន ១២៩៦គ្រួសារ ស្មើនឹង៦០០៤នាក់ (ស្រី៤០២៤ នាក់) ឃុំនេះមានភូមិចំនួន៩ ដែលមានពាក់ព័ន្ធនឹង ទីតាំងដីដែលក្រុមហ៊ុនស្នើសុំ ដូចមានក្នុងតារាងខាងក្រោម៖

១. តារាងស្ថិតិប្រជាពលរដ្ឋ(ឆ្នាំ២០០៩)ក្នុងភូមិពាក់ព័ន្ធនៅឃុំត្រពាំងជោ

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាជន | ស្រី | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ចំបក់ | ៦៨ | ២២៥ | ១៧៧ | |
| ២ | ត្រាង | ៨៦ | ២០៩ | ១១៩ | |
| ៣ | កោដូន្តី | ៨៧ | ១៨៨ | ៩៦ | |
| ៤ | ពុទ្រា | ៧០ | ៣៧០ | ១៨០ | |
| ៥ | សំរោង | ៤៩ | ២២២ | ១១០ | |
| ៦ | លាក់តាន | ២៣ | ១០៥ | ៨៧ | |
| ៧ | ក្រវៀក | ៥៦ | ២៦០ | ១៣៥ | |
| ៨ | ក្បាលដំរី | ៦៣ | ២៩៥ | ១៥៧ | |
| ៩ | ច្រកទៀក | ១៨២ | ៦២៦ | ៣៨៩ | |
| ១០ | តាជិល | ៥៩ | ២១៤ | ១០៧ | |
| **សរុប** | | **៦៦៣** | **២៧១៤** | **១៤៣៧** | |

២. តារាងស្ថិតិប្រជាពលរដ្ឋ(ឆ្នាំ២០០៩)ក្នុងភូមិពាក់ព័ន្ធនៅឃុំសង្កែសាទប

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាជន | ស្រី | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ដំបងវៀញ | ១០៣ | ៤៤៨ | ២២០ | |
| ២ | កន្ទួត | ៦៧ | ៣១០ | ១៣៩ | |

Draft

| | | | | | |
|---|---|---|---|---|---|
| ៣ | ជំនាប់ | ៨៤ | ៤០០ | ២០១ | |
| ៤ | តាដែស | ១០០ | ៤៧៦ | ២៤៨ | |
| ៥ | ក្រាំងពង្រ | ៦៤ | ២៩៧ | ១៥៣ | |
| សរុប | | ៤១៨ | ១៩៣១ | ៩៦១ | |

**១៦៧.** លំនាំនៃការតាំងទីលំនៅក្នុងតំបន់ពាក់ព័ន្ធទាំងនេះមានលក្ខណៈ (១) ការតាំងទីលំនៅតាមបណ្ដោយផ្លូវលេខ៥២ ផ្លូវលេខ៨៤ និងផ្លូវលំក្នុងឃុំ (២) ការតាំងទីលំនៅរបស់ប្រជាជនមានលក្ខណៈប្រមូលផ្ដុំនៅតាមភូមិនិមួយៗក្នុងឃុំ ដែលពីផ្ទះមួយទៅផ្ទះមួយសង់ឃ្លាតពីគ្នាដោយអន្លើមានចំងាយប្រមាណពី ៣០-៥០ម៉ែត្រ។ ប្រជាជនខ្លះមានដីស្រែចំការរបស់ខ្លួននៅក្បែរផ្ទះ និងខ្លះនៅឆ្ងាយចូលជ្រៅទៅក្នុង ព្រៃប្រហែល១-២គ.មពីផ្លូវពិសេសគឺនៅតាមមាត់អូរ និងជ្រលង់។

**១៦៨.** តាមការសិក្សារបស់ក្រុមការងារទៅលើតំបន់ដីសម្បទាននេះបង្ហាញថា នៅតំបន់នេះមិនមានសំណាក ឬសំណង់ប្រាសាទប្រវត្តិសាស្ត្រ ប៉ុន្តែ មានព្រៃមួយកន្លែង (ទីសក្ការៈគោល) មានផ្ទៃដីប្រមាណជិតមួយហិកតា ដែលអ្នកភូមិជនជាតិស្ទួយតែងតែគោរព ។

Draft